ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន
# គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ
# របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤១ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣០៦ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤១ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ហៅកាត់ថា លេខាធិការដ្ឋាន **គ.វ.អ.** ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ទ.អ.

**មាត្រា២ ._**

លេខាធិការដ្ឋាន **គ.ទ.អ.** មានតួនាទីជាសេនាធិការរបស់ **គ.ទ.អ.** ក្នុងការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងមានភារកិច្ចដូចខាងក្រោម៖

- ជួយ **គ.ទ.អ.** ក្នុងការបញ្ចូលវិធានការគន្លឹះក្នុងវិស័យអប់រំឱ្យបានសមស្រប តថភាព និងស័ក្តិសិទ្ធភាព តាមរយៈការពិនិត្យលើគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីពង្រឹងគុណភាពអប់រំសាលារដ្ឋ ចាប់ពីថ្នាក់មត្តេយ្យរហូតដល់មធ្យមសិក្សា
- ជួយ **គ.ទ.អ.** ក្នុងការរៀបចំនិងផ្សព្វផ្សាយគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការចាំបាច់នានា និងកំណត់នូវក្របខ័ណ្ឌសមិទ្ធកម្មដែលរួមមាន សូចនាករគន្លឹះ គោលដៅ និងវិធីសាស្ត្រវាស់វែងវឌ្ឍនភាព ដើម្បីពង្រឹងគុណភាពអប់រំសាលារដ្ឋចាប់ពីថ្នាក់មត្តេយ្យរហូតដល់មធ្យមសិក្សា ប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងសមិទ្ធកម្ម តាមរយៈ (១) ការពង្រឹងអភិបាលកិច្ចសាលារៀន (២) ការពិនិត្យកែលម្អកម្មវិធីសិក្សានិងរៀបចំកម្មវិធីសិក្សានិងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថសិស្ស (៣) ការយកចិត្តទុកដាក់លើសុខភាពសិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារនិងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា និង (៤) ការជំរុញនិងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក **ភាពជាដៃគូរដ្ឋនិងសហគមន៍ដើម្បីការអប់រំ**
- ជួយ **គ.ទ.អ.** ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពជាប្រចាំ ព្រមទាំងសិក្សាលើបញ្ហានិងការប្រឈម និងស្នើវិធានការដាក់ស្តែងឱ្យទាន់ពេលដើម្បីធានាភាពជោគជ័យនៃការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល
- ជួយ **គ.ទ.អ.** ក្នុងការពិនិត្យឡើងវិញលើក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងគោលការណ៍និងនីតិវិធី ប្រតិបត្តិការ និងលើកសំណើធ្វើវិសោធនកម្ម និង/ឬកែសម្រួលក្នុងករណីចាំបាច់ ដើម្បីធានាជំរុញការអនុវត្តវិធានការគន្លឹះប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងសមិទ្ធផល
- ជួយ **គ.ទ.អ.** ក្នុងការចុះគាំទ្រតាមសាលារៀនគោលដៅ ដើម្បីបណ្តុះនិងលើកកម្ពស់សមត្ថភាព ឆន្ទៈ ស្មារតី និងការចូលរួមរបស់នាយកសាលា គ្រូបង្រៀន និងសហគមន៍ ក្នុងការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ ប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាពខ្ពស់ និងសមិទ្ធផល
- អនុវត្តកិច្ចការទំនាក់ទំនងសាធារណៈរបស់លេខាធិការដ្ឋាន **គ.ទ.អ.**
- រៀបចំ គ្រប់គ្រង និងចាត់ចែងថវិការបស់ **គ.ទ.អ.**
- រៀបចំរបាយការណ៍ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន **គ.ទ.អ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រធាន **គ.ទ.អ.**។

## ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន គ.ទ.អ.

**មាត្រា៣ ._**

លេខាធិការដ្ឋាន **គ.ទ.អ.** ដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធាន សមាជិក ទីប្រឹក្សា អ្នកស្រាវជ្រាវ មន្ត្រីជំនាញ និងបុគ្គលិកបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត្យ។

ការបែងចែកភារកិច្ចនិងរបៀបការងាររបស់អនុប្រធាននិងសមាជិក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.**។

ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.** អាចជ្រើសរើសនិងចេញសេចក្តីសម្រេចតែងតាំង ទីប្រឹក្សា អ្នកស្រាវជ្រាវ មន្ត្រីជំនាញនិងបុគ្គលិកបច្ចេកទេសចេញពីមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ និង/ឬក្រៅក្របខ័ណ្ឌមុខងារសាធារណៈតាមការចាំបាច់ បន្ទាប់ពីទទួលការឯកភាពពីប្រធាន **គ.ទ.អ.** ។

**មាត្រា៤ ._**

លេខាធិការដ្ឋាន **គ.ទ.អ.** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៥ ._**

អនុប្រធាននិងសមាជិកលេខាធិការដ្ឋាន **គ.ទ.អ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.** អាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំការងារនិងកិច្ចប្រជុំជំនួស។

**មាត្រា៦ ._**

ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ មន្ត្រីជំនាញរបស់ក្រសួង ស្ថាប័ន និងទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ មកប្រជុំពិភាក្សានិងផ្តល់យោបល់ក្នុងក្របខ័ណ្ឌនៃការងាររបស់លេខាធិការដ្ឋានតាមការចាំបាច់។

ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.** អាចចេញសេចក្តីសម្រេចបង្កើតក្រុមការងារផ្សេងៗ បន្ទាប់ពីទទួលការឯកភាពពីប្រធាន **គ.ទ.អ.** ដើម្បីជួយការងាររបស់លេខាធិការដ្ឋាន **គ.ទ.អ.** តាមការចាំបាច់។

**មាត្រា៧ ._**

លេខាធិការដ្ឋាន **គ.ទ.អ.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- ផ្នែកគោលនយោបាយ។

២- ផ្នែកគាំទ្រសាលារៀន។

៣- ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

៤- ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈ។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន **គ.ទ.អ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨ ._**

ផ្នែកនីមួយៗមានក្រុមចំណុះជាសេនាធិការតាមការចាំបាច់។

ផ្នែកនីមួយៗនិងក្រុមចំណុះនៃផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានព្រមទាំងមានសមាជិកមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សមាសភាពផ្នែកនីមួយៗនិងក្រុមចំណុះនៃផ្នែកនីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.**។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមចំណុះនៃផ្នែកនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានលេខាធិការដ្ឋាន **គ.ទ.អ.** បន្ទាប់ពីទទួលការឯកភាពពីប្រធាន **គ.ទ.អ.**។

# ជំពូកទី៤
# ភារកិច្ចរបស់ផ្នែកនីមួយៗនៃលេខាធិការដ្ឋាន គ.ខ.អ.

**មាត្រា៩ ._**

ផ្នែកគោលនយោបាយមានភារកិច្ចដូចខាងក្រោម៖

- សិក្សា វិភាគ និងវាយតម្លៃលើគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព វិធានការនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងវិធានការគន្លឹះក្នុងវិស័យអប់រំពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាដោយផ្តោតលើកម្មវិធីសិក្សា អភិបាលកិច្ចសាលា សុខភាពសិស្ស និងការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ
- រៀបចំរបាយការណ៍ជូនប្រធានលេខាធិការដ្ឋាន **គ.ខ.អ.** ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព វិធានការចាំបាច់នានា ពាក់ព័ន្ធនឹងវិធានការគន្លឹះក្នុងវិស័យអប់រំ
- សិក្សា ស្រាវជ្រាវ និងលើកសំណើជូនប្រធានលេខាធិការដ្ឋាន **គ.ខ.អ.** អំពីផែនការសកម្មភាព និងវិធានការចាំបាច់នានា ព្រមទាំងវិធីសាស្ត្រវាស់វែងវឌ្ឍនភាពសមិទ្ធកម្ម សូចនាករគាំទ្រសម្រាប់ការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ
- ផ្សព្វផ្សាយផែនការសកម្មភាព វិធានការចាំបាច់នានា និងលទ្ធផលក្នុងការអនុវត្តវិធានការគន្លឹះ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ខ.អ.**។

**មាត្រា១០ ._**

ផ្នែកគាំទ្រសាលារៀនមានភារកិច្ចដូចខាងក្រោម៖

- កំណត់គោលការណ៍ជ្រើសរើសសាលារៀនគោលដៅដែលត្រូវគាំទ្រ
- រៀបចំកម្មវិធីនិងសៀវភៅណែនាំបច្ចេកទេសគាំទ្រសាលារៀន
- រៀបចំផែនការសកម្មភាពនិងចុះគាំទ្រនាយកសាលា គ្រូបង្រៀន សិស្ស និងសហគមន៍ នៅតាមសាលារៀនគោលដៅ
- តាមដាននិងវាយតម្លៃបទពិសោធនៃការអនុវត្តការគាំទ្រសាលារៀនគោលដៅ
- សម្របសម្រួលប្រមូលធាតុចូលពីក្រុមចំណុះផ្នែក និងភាគីពាក់ព័ន្ធ ដូចជាមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត នាយកសាលាចូលនិវត្តន៍ នាយកសាលា គ្រូបង្រៀន សិស្សានុសិស្ស មាតាបិតា ដៃគូអភិវឌ្ឍ និងវិស័យឯកជន
- ផ្សព្វផ្សាយពីឧត្តមានុវត្តន៍របស់សាលាគោលដៅ ដើម្បីជំរុញ លើកកម្ពស់ និងពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស និងវិធីសាស្ត្រលើកទឹកចិត្តឱ្យមានការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ខ.អ.**។

**មាត្រា១១ ._**

ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានភារកិច្ចដូចខាងក្រោម៖

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពជាប្រចាំ ព្រមទាំងសិក្សាលើបញ្ហានិងការប្រឈម ហើយស្នើវិធានការជាក់ស្តែងនិងទាន់ពេលដើម្បីធានាភាពជោគជ័យនៃការអនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល
- សិក្សា វិភាគ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើក្របខ័ណ្ឌសមិទ្ធកម្មដែលរួមមាន សូចនាករគន្លឹះ គោលដៅ និងវិធីសាស្ត្រវាស់វែងវឌ្ឍនភាពដែលបាននិងកំពុងអនុវត្តក្នុងផ្នែកការអប់រំពីថ្នាក់មត្តេយ្យ

ដល់មធ្យមសិក្សា ដើម្បីធានាសង្គតិភាព ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងសមិទ្ធផលបម្រើឱ្យគោលដៅលើកកម្ពស់គុណភាពការអប់រំ ពង្រឹងអភិបាលកិច្ចសាលា ពង្រឹងចំណេះដឹង វិន័យ សីលធម៌និងឥរិយាបទរបស់សិស្ស លើកកម្ពស់សុខភាពរបស់សិស្ស លើកទឹកចិត្តឱ្យមានការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សានៃវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល

- រៀបចំសូចនាករគន្លឹះ គោលដៅ និងវិធីសាស្ត្រវាស់វែងវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាព អនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ទ.អ.**។

**មាត្រា១២ .-**

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈមានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវលើរាល់កិច្ចការទំនាក់ទំនងសាធារណៈ កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ រួមទាំងលិខិតស្នាម ឯកសារពាក់ព័ន្ធ ការរៀបចំកិច្ចប្រជុំនិងរបាយការណ៍នានារបស់លេខាធិការដ្ឋាន **គ.ទ.អ.** និង **គ.ទ.អ.**
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសមស្របសម្រាប់ការទំនាក់ទំនង ចែកចាយ ផ្សព្វផ្សាយ កិច្ចប្រជុំសិក្ខាសាលា និងការបណ្តុះបណ្តាលនានា
- រៀបចំផែនការគម្រោងថវិកា ផែនការអនុវត្តថវិកា និងរបាយការណ៍ហិរញ្ញវត្ថុនានា ដើម្បីធានាស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា និងធានាដំណើរការប្រកបដោយ ផលិតភាព និងសមិទ្ធផលរបស់លេខាធិការដ្ឋាន **គ.ទ.អ.**
- ទទួលខុសត្រូវលើរាល់កិច្ចការគណនេយ្យនិងហិរញ្ញវត្ថុរួមទាំងការងារចំណាយ និងការទូទាត់នានា ដើម្បីធានាភាពត្រឹមត្រូវស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីគណនេយ្យនិងហិរញ្ញវត្ថុដែលមានជាធរមានរបស់លេខាធិការដ្ឋាន **គ.ទ.អ.** និង **គ.ទ.អ.**
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីពាក់ព័ន្ធរៀបចំយន្តការទំនាក់ទំនងសាធារណៈផ្សេងៗ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានលេខាធិការដ្ឋាន **គ.ទ.អ.**។

## ជំពូកទី៥
## ប្រភពធនធានរបស់លេខាធិការដ្ឋាន គ.ទ.អ.

**មាត្រា១៣ .-**

ប្រភពធនធានសម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់លេខាធិការដ្ឋាន **គ.ទ.អ.** មានថវិកាជាតិ ថវិកាដៃគូ និងប្រភពស្របច្បាប់ផ្សេងទៀត ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៤ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងប្រធាន អនុប្រធាន សមាជិក ទីប្រឹក្សា អ្នកស្រាវជ្រាវ មន្ត្រីជំនាញ បុគ្គលិកបច្ចេកទេស និងរចនាសម្ព័ន្ធចំណុះលេខាធិការដ្ឋាន **គ.ទ.អ.** ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៥ .-**

អនុក្រឹត្យលេខ៣១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៣៤៤អនក្រ.បក ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

**អង្គការលេខនៃរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.**

